# អនុក្រឹត្យលេខ ៩៦ អនក្រ .បក
## ស្តីពីការបង្កើតអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**មាត្រា ១.-** ត្រូវបានបង្កើតអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ (អក្សរកាត់ អ.ប.អ.ព) ក្រោមការគ្រប់គ្រងនៃអគ្គលេខាធិការដ្ឋានកំណែទំរង់រដ្ឋបាល ។

**មាត្រា ២ .-** អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ មានសមាសភាពដូចខាងក្រោម ៖

-ឯកឧត្តម ស៊ុំ ម៉ានិត អគ្គលេខាធិការកំណែទំរង់រដ្ឋបាល ជាប្រធាន

-ឯកឧត្តម ស៊ាន វិសុទ្ធ ទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាសមាជិកអចិន្ត្រៃយ៍

-ឯកឧត្តម មល់ ធឿន ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក

-ឯកឧត្តម យូ ស៊ុនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក

-ឯកឧត្តម សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

-ឯកឧត្តម គង ណែម អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាសមាជិក

-លោក ម៉ម និច ប្រធាននាយកដ្ឋានអធិការកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

-លោក ប៉ុល់ ចន្ទនារា ការិយាល័យមេធាវីរាជរដ្ឋាភិបាល ជាសមាជិក

-លោក យូ ខុន្ថា ប្រធានការិយាល័យនៃក្រសួងយុត្តិធម៌ ជាសមាជិក

មាត្រា ៣ .- អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយនេះ មានភារកិច្ចដូចតទៅ ៖

- សិក្សាស្រាវជ្រាវធ្វើរបាយការណ៍ និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីវិធានការបង្ការអំពើពុករលួយ ។
- ត្រួតពិនិត្យ ស៊ើបអង្កេត និងមានវិធានការចំពោះរាល់សកម្មភាពដែលពាក់ព័ន្ធនឹងអំពើពុករលួយ ។
- រៀបចំសិក្ខាសាលា និងអង្គប្រជុំផ្សព្វផ្សាយ ដើម្បីបង្កើនការចាប់អារម្មណ៍ថែមទៀត ចំពោះ អភិបាលកិច្ចល្អ ជាពិសេសការប្រឆាំង និងអំពើពុករលួយ ។
- រៀបចំបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីពង្រឹងការប្រឆាំងនឹងអំពើពុករលួយ ។

មាត្រា ៤ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងយុត្តិធម៌ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៥២១ អនក្រ .តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស//៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល